17/06/24

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
លេខ : ៧៨០ ទសណ.កបច

ថ្ងៃព្រហស្បតិ៍ ៧កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម**
**ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងជាប្រធានអាជ្ញាធរទន្លេសាប**

**កម្មវត្ថុ៖** ករណីសំណើសុំគោលការណ៍ដ៏ខ្ពង់ខ្ពស់ពីសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី ក្នុងការផ្ទេរលេខាធិការដ្ឋានបបនីយជីវមណ្ឌលបឹងទន្លេសាបនិងលេខាធិការ ពីគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាទៅអាជ្ញាធរទន្លេសាប។

**យោង ៖** -លិខិតលេខ៣៨០ គ.ជ.ទ.ម.ក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤ របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

-ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤ ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្ដីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលសម្រេចផ្ទេរលេខាធិការដ្ឋានបបនីយជីវមណ្ឌលបឹងទន្លេសាបនិងលេខាធិការ ពីគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ទៅស្ថិតក្នុងរចនាសម្ព័ន្ធនិងការគ្រប់គ្រងរបស់អាជ្ញាធរទន្លេសាប និងប្រគល់ភារកិច្ចជូនអាជ្ញាធរទន្លេសាប ដើម្បីពិនិត្យកែសម្រួលរចនាសម្ព័ន្ធស្ថាប័នរបស់ខ្លួនដោយដាក់បញ្ចូលលេខាធិការដ្ឋានបបនីយជីវមណ្ឌលបឹងទន្លេសាប និងដឹកនាំសម្របសម្រួលការពិភាក្សាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការគ្រប់គ្រងបបនីយជីវមណ្ឌលបឹងទន្លេសាប។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ប្រាជ្ញ សុចិន្ដា**

**ចម្លងជូន៖**
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- អាជ្ញាធរទន្លេសាប
- ឯកសារ កាលប្បវត្តិ